ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២៧ សសរ

# សេចក្ដីសម្រេច
## ស្ដីពី
## ការតែងតាំងសមាសភាពគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍

- បានឃើញអនុក្រឹត្យលេខ ១៦៨ អនក្រ.បក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៧៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ
- យោងតាមសំណើរបស់ប្រធានគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ

## សម្រេច

**ប្រការ១._**

ត្រូវបានតែងតាំងសមាសភាពគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ ដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២. ឯកឧត្តម **ថោង ខុន** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣. លោកជំទាវបណ្ឌិតសភាចារ្យ **ភឿង សកុណា** | រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា | អនុប្រធាន |
| ៤. ឯកឧត្តម **សាយ សំអាល់** | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | អនុប្រធាន |
| ៥. ឯកឧត្តម **ស៊ុន ចាន់ថុល** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៦. ឯកឧត្តម **លឹម គានហោ** | រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប | សមាជិក |
| ៧. ឯកឧត្តម **ជា វ៉ាន់ដេត** | រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគម | សមាជិក |
| ៨. ឯកឧត្តម **ម៉ម ប៊ុនហេង** | រដ្ឋមន្ត្រីក្រសួងសុខាភិបាល | សមាជិក |
| ៩. ឯកឧត្តម **ឈិត សុខុន** | រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា | សមាជិក |
| ១០. ឯកឧត្តម **ប៉ាន សូរស័ក្តិ** | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១១. ឯកឧត្តម **ម៉ៅ ហាវណ្ណាល់** | រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១២. ឯកឧត្តម **ធិត ចន្ថា** | រដ្ឋលេខាធិការប្រចាំការក្រសួងទេសចរណ៍ | សមាជិក |
| ១៣. ឯកឧត្តម **គុល ទីរក្ស** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១៤. ឯកឧត្តម **កែន សត្ថា** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៥. ឯកឧត្តមបណ្ឌិត **ឈុន សុភាព** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១៦. ឯកឧត្តម **ជា បូរ៉ា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១៧. ឯកឧត្តម **សុខ គុនហាប់** | តំណាងក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា | សមាជិក |

| | | |
|---|---|---|
| ១៨. ឯកឧត្តម **តុប សុគ័ក** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១៩. ឯកឧត្តម **ញ៉ឹម ខេមរា** | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ២០. ឯកឧត្តម **ម៉ែន សុផល** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ២១. ឯកឧត្តម **ជួន ធន** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ២២. ឯកឧត្តម **សុខ ខាទ៉ាន់** | រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | សមាជិក |
| ២៣. ឯកឧត្តម **ហាប់ អូម៉ាលី** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ២៤. ឯកឧត្តម **ឡៅ ហ៊ឹម** | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២៥. ឯកឧត្តម **ហាស់ សារ៉េត** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ២៦. ឯកឧត្តម **សុខ ចិន្តាសោភា** | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ២៧. ឯកឧត្តមនាយឧត្តមសេនីយ៍សន្តិបណ្ឌិត **នេត សាវឿន** | អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ២៨. ឯកឧត្តមនាយឧត្តមសេនីយ៍ **សៅ សុខា** | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ២៩ ឯកឧត្តម **ទៀ សីហា** | អភិបាលនៃគណៈអភិបាលខេត្តសៀមរាប | សមាជិកប្រចាំការ |
| ៣០. ឯកឧត្តម **សុខ សប្បាយណា** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៣១. ឯកឧត្តម **ហង់ ពៅ** | អគ្គនាយកអាជ្ញាធរជាតិអប្សរា | សមាជិក |
| ៣២. ឯកឧត្តម **លី សែ** | អគ្គនាយកគ្រឹះស្ថានអង្គរ | សមាជិក |
| ៣៣. ឯកឧត្តម **កែវ រតនៈ** | អគ្គនាយកអគ្គិសនីកម្ពុជា | សមាជិក |
| ៣៤. ឯកឧត្តម **ខូច មាស** | អគ្គលេខាធិការរងអាជ្ញាធរទន្លេសាប | សមាជិក |
| ៣៥. ឯកឧត្តម **ឈាប សាមុត** | អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ និងជាប្រធានលេខាធិការដ្ឋាន គ.អ.ទ.ស. | សមាជិក។ |

**ប្រការ២.**_

សមាជិកនៃគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ មានភារកិច្ចអនុវត្តការងារទៅតាមការតម្រង់ទិសរបស់អនុក្រឹត្យលេខ**២៧៦** អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០**២១** ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ។

**ប្រការ៣.**_

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.**_

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៤រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមេសា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :

- ខុទ្ទកាល័យ**សម្តេចអគ្គមហាសេនាបតីតេជោ**នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ